ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៤.អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកែសម្រួលបៀវត្សមូលដ្ឋាននិងការបើកផ្តល់បៀវត្ស ដល់យោធិននៃកងយោធពលខេមរភូមិន្ទ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការកែសំរួលប្រព័ន្ធបៀវត្សរបស់កងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

សម្រេច

មាត្រា១ .-

អនុក្រឹត្យនេះ មានគោលបំណងដើម្បីរៀបចំការកំណត់បៀវត្សមូលដ្ឋាន និង ការបើកផ្តល់បៀវត្សប្រចាំខែដល់យោធិននៃកងយោធពលខេមរភូមិន្ទ។

www.pheakdeylaw.com

មាត្រា២ .-

អនុក្រឹត្យនេះ មានគោលដៅកំណត់៖

- កម្រិតសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់យោធិននៃកងយោធពលខេមរភូមិន្ទ
- ការបើកផ្តល់បៀវត្សប្រចាំខែរបស់យោធិនតាមប្រព័ន្ធធនាគារ លើកលែងយោធិនដែលមានការអនុញ្ញាតដោយឡែកដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ។

មាត្រា៣ .-

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ។

មាត្រា៤ .-

បៀវត្សមូលដ្ឋានរបស់យោធិននៃកងយោធពលខេមរភូមិន្ទ ត្រូវបានរៀបចំបែងចែកតាមលំដាប់នៃឋានន្តរស័ក្តិនិងត្រូវបានផ្តល់នូវកម្រិតសន្ទស្សន៍ ដូចមានកំណត់ក្នុងតារាងខាងក្រោម៖

ល.រ	ឋានន្តរស័ក្តិ		កម្រិតសន្ទស្សន៍បៀវត្សមូលដ្ឋាន
១	នាយឧត្តមសេនីយ៍	នាយឧត្តមនាវី	៥៥០
២	ឧត្តមសេនីយ៍ឯក	ឧត្តមនាវីឯក	៥៣១
៣	ឧត្តមសេនីយ៍ទោ	ឧត្តមនាវីទោ	៥១៣
៤	ឧត្តមសេនីយ៍ត្រី	ឧត្តមនាវីត្រី	៤៩៦
៥	វរសេនីយ៍ឯក	វរនាវីឯក	៤៧៩
៦	វរសេនីយ៍ទោ	វរនាវីទោ	៤៦១
៧	វរសេនីយ៍ត្រី	វរនាវីត្រី	៤៤៣
៨	អនុសេនីយ៍ឯក	អនុនាវីឯក	៤០៧
៩	អនុសេនីយ៍ទោ	អនុនាវីទោ	៣៨០
១០	អនុសេនីយ៍ត្រី	អនុនាវីត្រី	៣៤៤
១១	នាយចំណង់	នាយនាវីចំណង់	៣៣១
១២	ព្រឹន្ទបាលឯក	នាយចក្របាលឯក	៣១៨
១៣	ព្រឹន្ទបាលទោ	នាយចក្របាលទោ	៣០០
១៤	ពលបាលឯក	ចក្របាលឯក	២៨៤
១៥	ពលបាលទោ	ចក្របាលទោ	២៧៤
១៦	ពលបាលត្រី	ចក្របាលត្រី	២៦៥
១៧	នាយឯក	ចក្របាលរងឯក	២៥០
១៨	នាយទោ	ចក្របាលរងទោ	២៤៥
១៩	ពលឯក	នាវិកឯក	២៤០
២០	ពលទោ	នាវិកទោ	២៣៥

កម្រិតសន្ទស្សន៍បៀវត្សមូលដ្ឋានខាងលើ ត្រូវចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥។

www.pheakdeylaw.com

មាត្រា៥ .-

តម្លៃឯកតាសន្ទស្សន៍សម្រាប់អនុវត្តនិងការកែប្រែតម្លៃឯកតាសន្ទស្សន៍ ត្រូវអនុវត្តតាមអនុក្រឹត្យស្តីពីតម្លៃឯកតានៃសន្ទស្សន៍សម្រាប់បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល។

មាត្រា៦ .-

យោធិនដែលមានសិទ្ធិទទួលបៀវត្សប្រចាំខែ ត្រូវស្ថិតក្នុងលក្ខខណ្ឌដូចខាងក្រោម៖

- កំពុងបំពេញការងារក្នុងកងយោធពលខេមរភូមិន្ទ
- កំពុងផ្លាស់ប្តូរកន្លែងធ្វើការនិងកំពុងធ្វើដំណើរទៅកាន់មុខតំណែងនៅក្នុងឬក្រៅប្រទេស
- កំពុងបំពេញការសិក្សាក្នុងឬក្រៅប្រទេសតាមតម្រូវការរបស់កងទ័ព
- យោធិនពលី ពិការ មរណៈ និវត្តជន បាត់បង់សមត្ថភាពការងារដែលមិនទាន់ផ្ទេរទៅឱ្យក្រសួងទទួលបន្ទុកអតីតយុទ្ធជនគ្រប់គ្រងបន្ត
- យោធិនដែលទទួលការអនុញ្ញាតច្បាប់ក្នុងចុះផ្ទាល់ រយៈពេលសម្រាកព្យាបាលជម្ងឺ និងបាត់ខ្លួនក្នុងបេសកកម្ម។

មាត្រា៧ .-

ការបញ្ឈប់ការបើកផ្តល់បៀវត្សប្រចាំខែ ត្រូវអនុវត្តចាប់ពីកាលបរិច្ឆេទកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ ក្នុងករណីដូចខាងក្រោម៖

- យោធិនដែលសុំលាឈប់ពីការងារដោយមានការអនុញ្ញាត
- យោធិនដែលមានប្រកាសបណ្តេញចេញពីកងយោធពលខេមរភូមិន្ទ
- យោធិនដែលអវត្តមានគ្មានការអនុញ្ញាតឬហួសកំណត់ដោយសម្អាងលើប្រធានស័ក្តិដែលមិនសមស្រប
- យោធិនពលី ពិការ មរណៈ និវត្តជន បាត់បង់សមត្ថភាពការងារដែលបានផ្ទេរទៅឱ្យក្រសួងទទួលបន្ទុកអតីតយុទ្ធជនគ្រប់គ្រងបន្តរួចហើយ
- យោធិនដែលបាត់បង់ឋានន្តរស័ក្តិតាមសាលក្រមឬសាលដីកាស្ថាពររបស់តុលាការ។

មាត្រា៨ .-

របបឧបត្ថម្ភផ្សេងៗរបស់យោធិនក្រៅពីបៀវត្សមូលដ្ឋាន ត្រូវបន្តអនុវត្តរហូតដល់មានការកែប្រែជាថ្មី។

មាត្រា៩ .-

បៀវត្សប្រចាំខែរបស់យោធិន ត្រូវបើកផ្តល់តាមប្រព័ន្ធធនាគារ។ ក្រសួងការពារជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ត្រូវសហការរៀបចំការបើកផ្តល់បៀវត្សប្រចាំខែដល់យោធិនតាមប្រព័ន្ធធនាគារស្របតាមលទ្ធភាពសេវារបស់ធនាគារនិងស្ថានភាពជាក់ស្តែងរបស់កងឯកភាពនីមួយៗ។

មាត្រា១០ .-

អនុក្រឹត្យលេខ១៨៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការកែសម្រួលប្រាក់បៀវត្សមូលដ្ឋានរបស់កងយោធពលខេមរភូមិន្ទ ត្រូវទុកជានិរាករណ៍។

www.pheakdeylaw.com

មាត្រា១១.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ២០១៥

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងការពារជាតិ **ទៀ បាញ់**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **អូន ព័ន្ធមុនីរ័ត្ន**

រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ **ពេជ្រ ប៊ុនធិន**

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

www.pheakdeylaw.com